# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ រាជរដ្ឋាភិបាលខ្មែរគួរកែកន្លែងដែលមានកំហុស
## កុំឲ្យក្លាយជារបបផ្តាច់ការ ។

www.hoksavann.org

ថ្ងៃទី២២ ធ្នូ ២០១១



តាមរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ខ្មែរកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស ពុំមែនជារបបកុម្មុយនិស្ត ពុំមែនជារបបផ្តាច់ការឡើយ ។ របបនេះបើកឲ្យមានគណបក្សនយោបាយច្រើនប្រណាំងប្រជែងគ្នាឲ្យប្រជាពលរដ្ឋបោះឆ្នោត បើគណបក្សណាបានតំណាងរាស្ត្រច្រើនក្នុងរដ្ឋសភាគ្រប់ចំនួនតាមកំណត់ គណបក្សនោះអាចបង្កើតរដ្ឋាភិបាលដឹកនាំប្រទេសផ្នែកនីតិប្រតិបត្តិ ចំណែកគណបក្សដែលមានសម្លេងតិច ទៅជាគណបក្សប្រឆាំង ។ គណបក្សកាន់អំណាចក្តី, គណបក្សប្រឆាំងក្តី រួមគ្នាធ្វើការតាមមុខងាររបស់ខ្លួន ដើម្បីឲ្យប្រទេសគង់វង់មានសន្តិភាព និងមានអភិវឌ្ឍនភាព ។

ក្រឡេកមើលគណបក្សនយោបាយខ្មែរបច្ចុប្បន្ន ទាំងគណបក្សកាន់អំណាច ទាំងគណបក្សប្រឆាំង ហាក់ដូចជាពុំបានអនុវត្តឲ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនេះឡើយ ហាក់ដូចជានៅតែប៉ែងជើងគ្នាក្រៅរង្វង់ច្បាប់ ។ គណបក្សប្រឆាំងមានសិទ្ធិឲ្យយោបល់ទៅគណបក្សកាន់អំណាចយកទៅពិចារណា តែបែរជាគណបក្សកាន់អំណាចប្តឹងគណបក្សប្រឆាំងដាក់ពន្ធនាគារទៅវិញ ដូចករណីដកបង្គោលតម្រុយព្រំដែន និងករណីឯកសារព្រំដែនជាដើម ។ ឯកសារដែលគណបក្សប្រឆាំងស្រាវជ្រាវឃើញ ទោះបីផ្ទុយពីឯកសាររបស់រាជរដ្ឋាភិបាលក៏ដោយ ក៏ត្រូវតែលើកយកមកពិនិត្យពិចារណារួមគ្នាដើម្បីប្រយោជន៍ជាតិ មិនត្រូវដាក់ទោសអ្នកមានយោបល់ផ្ទុយឡើយ ។ ចំណែកតុលាការកាត់សេចក្តីបញ្ហានេះពុំយុត្តិធម៌ឡើយ ជាតុលាការខ្លាចអំណាចរាជរដ្ឋាភិបាល (ភយាគតិ) កាត់សេចក្តីឲ្យអ្នកកាន់អំណាចឈ្នះព្រោះខ្លាចអំណាច ។ តុលាការកាត់សេចក្តីប្រកបដោយអគតិធម៌ដូច្នេះ មានទោសធ្ងន់ណាស់ ព្រោះធ្វើឲ្យអ្នកត្រូវទៅជាខុស អ្នកខុសទៅជាត្រូវវិញ ។ ចៅក្រមនោះគួរលាលែងពីតំណែង កុំកាត់សេចក្តីដោយអយុត្តិធម៌ដូចនេះឡើយ ។

បញ្ហាមួយទៀត ខ្មែរម្ចាស់ដីបានក្រោកឡើងប្រឆាំងនឹងពួកអ្នកធំអ្នកមានអំណាចពួកឧកញ៉ារំលោភយកដីរបស់ខ្លួន បានត្រូវគេវាយធ្វើបាប រហូតបាញ់ឲ្យរបួសទៀតផង ដោយប៉ូលិសស៊ីឈ្នួលឲ្យអ្នកមានអំណាចទាំងនោះ ។ ពលរដ្ឋគ្មានកាន់គ្រឿងសាស្ត្រាវុធមានកាំភ្លើងជាដើម ពេលដែលគេមកឈូសដីរំលំផ្ទះបានកើតកំហឹង ក៏យកដុំដីដុំថ្មចោលដេញអ្នករំលោភទាំងនោះ បានត្រូវគេបាញ់ដោយយកលេសថាបាញ់ការពារខ្លួន ។ បាញ់ការពារខ្លួន លុះត្រាតែមានការគំរាមកំហែងដល់ជីវិត ចុះពលរដ្ឋគ្មានកាំភ្លើងក្នុងដៃ ប៉ូលិសគ្រាន់តែដកខ្លួនចេញទុកជាការស្រេចគ្មានគ្រោះថ្នាក់អ្វីឡើយ មិនត្រូវប្រើអាវុធបាញ់ទៅលើប្រជាពលរដ្ឋឡើយ ។ ការបាញ់ដោយចេតនានេះចាត់ជាអំពើឧក្រិដ្ឋ ត្រូវតែកាត់ទោសក្នុងតុលាការ ។ គួរឲ្យសង្វេគមួយទៀតប្រជាពលរដ្ឋនៅបឹងកក់មានកំហឹងដោយសារក្រុមហ៊ុនមកឈូសផ្ទះខ្លួន ក៏ប្រើពាក្យគ្រោតគ្រាតខ្លះ ស្រាប់តែតុលាការនៅភ្នំពេញកោះហៅពលរដ្ឋ៨នាក់ទៅដាក់ឃុំដោយចោទថាប្រមាថមើលងាយរដ្ឋអំណាច តែត្រង់ក្រុមហ៊ុនដែលមានអភិបាលក្រុងនៅពីក្រោយឈូសរំលំផ្ទះប្រជាពលរដ្ឋ បែរជារួចខ្លួនគ្មានទោសអ្វីសោះ ។ នេះជាអំពើរបស់រដ្ឋអំណាចក្រុងរំលោភមកលើប្រជាពលរដ្ឋដោយអយុត្តិធម៌ ។ មួយទៀត សាលាក្រុងភ្នំពេញបានបង្កើតបញ្ហាលើបញ្ហា ដោយប្រមុខដឹកនាំរដ្ឋាភិបាលបានចេញច្បាប់ប្រគល់ដីជាង១២ហិកតាឲ្យអ្នកបឹងកក់មួយក្រុមដែលមិនព្រមចេញពីទីនោះ សុខចិត្តអភិវឌ្ឍន៍នៅនឹងកន្លែង បែរជាសាលាក្រុងបែងចែកគ្រួសារខ្លះឲ្យ គ្រួសារខ្លះមិនឲ្យទៅវិញ ។ ប្រជាពលរដ្ឋសុទ្ធតែក្រីក្រ គួរប្រគល់ឲ្យទាំងអស់គ្នា មិនត្រូវលើកយកលក្ខខណ្ឌបែបណាមួយ ដូចលើកឡើងថា គ្រួសារនេះមកកាន់ទីនេះមុន គ្រួសារនោះមកនៅទីនេះក្រោយឡើយ នេះទើបឈ្មោះថា ដោះស្រាយតាមបែបមនុស្សធម៌ ទើបបញ្ចប់បញ្ហានៅបឹងកក់ ។ ការធ្វើវិនិយោគទុន ដើម្បីធ្វើឲ្យប្រទេសបានលូតលាស់ចំរើន ប្រជាពលរដ្ឋពុំជំទាស់ទេ ប៉ុន្តែជំទាស់នៅត្រង់ធ្វើទៅប៉ះទៅលើដីទៅលើផ្ទះរបស់ប្រជាពលរដ្ឋ មិនបានសងតម្លៃជូនប្រជាពលរដ្ឋឲ្យមានតម្លាភាពតាមទីផ្សារ ។ យើងដឹងហើយថា មេក្រុមហ៊ុនទាំងនោះជាឧកញ៉ា ជាព្រឹទ្ធសភា ជាទីប្រឹក្សារបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាលខ្មែរ ដូច្នេះហើយបានជាកាន់ជើងអ្នកទាំងនោះ ប៉ុន្តែសូមកុំភ្លេចថា ប្រជាពលរដ្ឋជាម្ចាស់នៃអំណាច ហើយយុត្តិធម៌ជាគោលគ្រឹះនៃរបបប្រជាធិបតេយ្យ ។

សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាលមានរាប់ពាន់នៅប្រទេសកម្ពុជា ទៅជួយខ្មែរស្ទើរគ្រប់វិស័យ ដើម្បីបំបាត់ភាពក្រីក្រនៃពលរដ្ឋខ្មែរ ប៉ុន្តែឥឡូវនេះ រាជរដ្ឋាភិបាលខ្មែរបានព្រាងច្បាប់គ្រប់គ្រងសង្គមស៊ីវិលនិងអង្គការមែនមែនរដ្ឋាភិបាលទាំងនោះ ។ ពង្រាងច្បាប់នោះមានប្រតិកម្មប្រឆាំងជាខ្លាំងពីអង្គការទាំងនោះ ពិសេសពីអង្គការសហប្រជាជាតិ ថាមិនគួរបង្កើតឲ្យមានច្បាប់នេះទៀតទេ ព្រោះខ្មែរមានច្បាប់សំរាប់ធ្វើទោសអ្នកមានកំហុសរួចហើយ ។ គេយល់ថា ការធ្វើច្បាប់នេះឡើងសំរាប់កៀបសង្កត់អង្គការទាំងនោះ ។ តាមពិត អង្គការទាំងនេះបានជួយខ្មែរ បើធ្វើច្បាប់កៀបសង្កត់ធ្វើឲ្យគេពិបាកបំពេញការងារ គេនឹងបិទត្រឡប់ទៅស្រុកគេវិញ នោះនឹងខាតប្រយោជន៍ខ្មែរ ។ គោលបំណងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើច្បាប់នេះគឺបើចង់បិទអង្គការណា រាជរដ្ឋាភិបាលអាចបិទបានដោយងាយ ។

គណបក្សកាន់អំណាច ហាក់ដូចជាចាំតែចាប់កំហុសគណបក្សប្រឆាំងជាប់ជានិច្ច ដូចជាពេលថ្មីៗនេះ សភារបស់គណ-

បក្សប្រជាជន (ពេលដកគណបក្សប្រឆាំងបានដើរចេញ) បានលើកដៃដកតំណាងរាស្ត្រគណបក្សប្រឆាំងម្នាក់ ដោយមិនបានស៊ើបអង្កេតឲ្យបានម៉ត់ចត់មុនប្រជុំគ្នាដកឡើយ គ្រាន់តែមានសំណើភ្លាម កោះហៅប្រជុំភ្លាម ។ ទង្វើរបស់សភាខ្មែរខាងនីតិបញ្ញត្តិបែបនេះ គ្មានធ្វើសកម្មភាពអ្វីក្រៅតែពីចាំប្រថាប់ត្រាប៉ុណ្ណោះ ដូចជាសភារបស់ខ្មែរក្រហមពេលដាក់ទិសពីមជ្ឈិមបក្សភ្លាមធ្វើតាមភ្លាម ។ តើសភាខ្មែរដែលស៊ីប្រាក់ខែពីរាស្ត្រមានប្រយោជន៍អ្វីដល់ជាតិ បើសភាខ្មែរចាំតែហៃអើដូចសត្វសេក ។ ការបង្កើតឲ្យមានសភាដែលមិនបានបំពេញមុខងាររបស់ខ្លួន ដេញដោលរដ្ឋាភិបាលក្នុងការដឹកនាំរដ្ឋ ទោះបីរដ្ឋាភិបាលនោះជាបក្សរបស់ខ្លួនក៏ដោយមិនមានប្រយោជន៍ដល់ជាតិឡើយ។នៅសហរដ្ឋអាមេរិកសភាខាងគណបក្សប្រជាធិបតេយ្យ តែងតែសួរដេញដោលរដ្ឋាភិបាល ទោះបីរដ្ឋាភិបាលនោះជាបក្សរបស់ខ្លួនក៏ដោយ មុននឹងសំរេចចិត្តគាំទ្រឬមិនគាំទ្រនូវគ្រប់សំណើដែលដាក់ជូនមកសភា ។ ត្រង់នេះខុសគ្នាពីសភាខ្មែរបច្ចុប្បន្ន ឲ្យតែរដ្ឋាភិបាលជាបក្សរបស់ខ្លួនស្នើមក គ្មានជជែក គ្មានសួរដេញដោលអ្វីឡើយ ចាំតែលើកដៃយល់ព្រម ។ បើឡើងនិយាយវិញ គ្មាននិយាយអ្វីក្រៅតែពីសរសើរនិងការពាររដ្ឋាភិបាលជាបក្សរបស់ខ្លួន ហើយវាយប្រហារគណបក្សប្រឆាំងជំនួសរដ្ឋាភិបាលប៉ុណ្ណោះ តើការវិភាគនេះពិតឬទេ ? ។៚

* *

*